អង្គការ ស៊ី អារ អេស

គំរោងកម្មវិធីកសិកម្ម ខេត្តស្វាយរៀង

របាយការណ៍វគ្គបណ្តុះបណ្តាលស្តីពី

# បច្ចេកទេសបំប៉នកូនត្រី ក្នុងហាប៉ា និង ក្នុងស្រះ



23-24 October,2002

# មាតិកា

ទំព័រ

## ពត៌មានទូទៅ


១. សេចក្តីផ្តើម : .................................................. ១

២. គោលបំណងនៃវគ្គបណ្តុះបណ្តាល : .................................................. ១

៣. សេចក្តីរំពឹងទុក : .................................................. ១

៤. វិធីសាស្ត្រ : .................................................. ១- ២

៥. ពេលវេលា និង ទីកន្លែង : .................................................. ២


## ខ្លឹមសារ និង លទ្ធផល

### I.ការបំប៉នកូនត្រីក្នុងហាប៉ា :


១. បច្ចេកទេសដេរហាប៉ា : .................................................. ៣

២. ការតំឡើងហាប៉ាក្នុងស្រះ : .................................................. ៤

៣. ចំនួនកូនត្រីដែលត្រូវដាក់ក្នុងហាប៉ា : .................................................. ៥

៤. ប្រភេទចំណីដែលត្រូវផ្តល់អោយកូនត្រី : .................................................. ៦

៥. បរិមាណចំណី និង ការផ្តល់ចំណី : .................................................. ៦-៧

៦. ចំណីធម្មជាតិ : .................................................. ៧-៨

៧. ការសំអាតហាប៉ា និង ថែទាំកូនត្រី : .................................................. ៨-៩


### II.ការបំប៉នកូនត្រីក្នុងស្រះ :


១. ស្រះសមស្របសំរាប់បំប៉នកូនត្រី :.................................................. ១០

២. ការរៀបចំស្រះបំប៉ន : .................................................. ១០

៣. ការលែងកូនត្រី : .................................................. ១១-១២

៤. ការថែទាំ : ............................................................ ១២-១៣

៥. ការប្រមូលផល និង លក់កូនត្រី : ............................................ ១៣

**III.ការដឹកជញ្ជូនកូនត្រី :**

១. ការដឹកជញ្ជូនដោយប្រើថង់ផ្លាស្ទិច : ........................................ ១៤

២. ការដឹកជញ្ជូនដោយប្រើធុង ឬ ធ្នាំង : ........................................ ១៥

**សន្និដ្ឋាន :** ............................................................ ១៦

**ឧបសម្ព័ន្ធ :**

- កម្មវិធីបណ្ដុះបណ្ដាល : ................................................. ១៧
- បញ្ជីឈ្មោះអ្នកចូលរួម : ................................................. ១៨
- តារាងពិន្ទុសំនួរសាកល្បង : .............................................. ១៨
- សកម្មភាពតាមរយៈរូបភាព : ............................................. ១៩-២១

# ពត៌មានទូទៅ

## ១. សេចក្តីផ្តើម :

ការបំប៉នកូនត្រីជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងការចិញ្ចឹមត្រី ។ កសិករទទួលបាន ជោគជ័យនៅក្នុងការចិញ្ចឹមត្រីទាល់តែពួកគាត់មានកូនត្រីពូជដែលមានគុណភាពល្អសំរាប់ដាក់ចិញ្ចឹម ។ នៅក្នុងឆ្នាំនេះដែលមានកសិករ ២ នាក់បានចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងការបំប៉នកូនត្រីសំរាប់លក់ចែកចាយអោយកសិករចិញ្ចឹម ដោយមានការគាំទ្រពីកសិករផលិត និង គំរោង។ ទោះជាយ៉ាងណាក៏ដោយ កសិករទាំងនោះនៅតែត្រូវការ ការគាំទ្រពីអ្នកបច្ចេកទេសរបស់គំរោងសំរាប់សកម្មភាពរបស់ពួកគាត់ ។

## ២. គោលបំណងនៃវគ្គបណ្តុះបណ្តាល :

- ពង្រឹងសមត្ថភាព និងផ្តល់ចំណេះដឹងបន្ថែមដល់កសិករបំប៉នលើបច្ចេកទេសបំប៉នកូនត្រី
- ដើម្បីអោយកសិករជួបពិភាក្សាពីបញ្ហាជួបប្រទះ ដំណោះស្រាយនៅក្នុងការបំប៉នកូនត្រី និង មានទំនាក់ទំនងល្អ
- បង្កើនគុណភាពកូនត្រីសំរាប់លក់អោយកសិករចិញ្ចឹម និង ផ្ទេរការបណ្តុះបណ្តាល ទៅអោយកសិករដែលចាប់អារម្មណ៍ ។

## ៣. សេចក្តីរំពឹងទុក :

- កសិករ ៨ នាក់បានទទួលការបណ្តុះបណ្តាល និង ទទួលបាននូវបច្ចេកទេសដែលបានរៀនសូត្រ
- កសិករ៨ នាក់ អាចបំប៉នកូនត្រីដែលមានគុណភាពល្អដើម្បីលក់អោយកសិករចិញ្ចឹម
- កសិករ ៨ នាក់អាចផ្តល់បច្ចេកទេសដល់កសិករដែលបានមកទិញកូនត្រី ។

## ៤. វិធីសាស្ត្រ :

- ទ្រឹស្តី
- ការអនុវត្តផ្ទាល់

- សំនួរសាកល្បងមុន និង ក្រោយពេលរៀន
- សំនួរ និង ចំលើយ
- ផ្តល់សៀវភៅមេរៀន
- បង្ហាញរូបភាព
- ទស្សនះកិច្ចការបំប៉នទៅផ្ទះគ្រូកសិករ

**៥. ទីកន្លែង និង ពេលវេលា :**

- វគ្គបណ្តុះបណ្តាលនេះមានរយះពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី ២៣-២៤ ខែ តុលា ឆ្នាំ២០០២ នៅភូមិទួលអំពិល ឃុំ ច្រកម្ទេស ។

# ខ្លឹមសារ និង លទ្ធផល

# I. ការបំប៉នកូនត្រីនៅក្នុងហាប៉ា :

## ១. បច្ចេកទេសដេរហាប៉ា :

ដើម្បីផលិតហាប៉ាសំរាប់បំប៉នកូនត្រីយើងត្រូវ :

- យកសាច់អញ្ចូងខៀវ ឬ សំណាញ់ខៀវ មកដេរអោយមានរាងដូចមុងដេក
- ហាប៉ាផ្គុំឡើងដោយ សំណាញ់ ៥ផ្ទាំងគឺ បាតក្រោម ១ផ្ទាំង ចំហៀងបណ្តោយ ២ ផ្ទាំង និង ចំហៀងទទឹង ២ ផ្ទាំង
- ហាប៉ាត្រូវដេរអោយមានត្រចៀកបួន នៅជ្រុងផ្នែកបាត និង មានត្រចៀកពី ១០-១២ នៅផ្នែកមាត់លើ ដើម្បីងាយស្រួលចងភ្ជាប់ទៅនឹងបង្គោល
- ទំហំហាប៉ាដែលកសិករនិយមប្រើគឺ បណ្តោយ ៣ម៉ែត្រ ទទឹង ២ម៉ែត្រ និង កំពស់ ១ ម៉ែត្រ ។



២. ការតំឡើងហាប៉ាក្នុងស្រះ

ដើម្បីតំឡើងហាប៉ាក្នុងស្រះយើងត្រូវ :

- មានបង្គោលឈើ ឬ ឫស្សីចំនួន ៤ដើមសំរាប់ចងហាប៉ា
- ដាក់ហាប៉ានៅជ្រុងស្រះ ឬ កន្លែងមានទឹករាក់ល្មមប្រហែល ១ម៉ែត្រ ដើម្បីងាយស្រួលត្រួតពិនិត្យ
- ហាប៉ាត្រូវដាក់កន្លែងណាដែលមានពន្លឺថ្ងៃគ្រប់គ្រាន់
- បាតហាប៉ាត្រូវលិចចូលទៅក្នុងទឹកជំរៅ ៥០-៧០ ស.ម ហើយមាត់ខាងលើនៃហាប៉ាត្រូវអោយខ្ពស់ផុតពីទឹកពី ៣០-៥០ ស.ម ដើម្បីការពារត្រីកាចលោតចូល និង ទឹកភ្លៀងជន់ ។
- ហាប៉ាត្រូវចងឃ្លាតពីមាត់ច្រាំងពី ១.៥- ២ម ដើម្បីការពារកង្កែបលោតចូល និងធ្វើអោយខ្យល់បក់ប៉ះផ្ទៃទឹកក្នុងហាប៉ាធ្វើអោយ អុកស៊ីសែន កើនឡើង ។
- បាតហាប៉ាត្រូវដាក់អោយផុតពីបាតស្រះដើម្បីការពារក្តាមកាត់
- បើសិនបាតហាប៉ាអណ្តែត ឬ ប៉ោងឡើងយើងត្រូវយកដុំឥដ្ឋ ឬ ដុំថ្មដាក់នៅចំកណ្តាលបាតហាប៉ា



៣. ចំនួនកូនត្រីដែលត្រូវដាក់ក្នុងហាប៉ា :

- នៅពេលកូនត្រីទីឡាព្យ៉ានៅក្នុងស្រះញាស់យើងអាចដង ឬ ដួសយកមកបំប៉ន បាន
- ចំពោះកូនត្រីកាបសាមញ្ញ និង កូនត្រីឆ្ពិនដែលមានអាយុពី ១០-១៥ ថ្ងៃ ឬ ទំហំពី ១-២ ស.ម អាចយកមកបំប៉នក្នុងហាប៉ាបាន
- ហាប៉ាដែលមានទំហំ ៣ ម x ២ម x ១ ម អាចដាក់កូនត្រីពី ១៥០០-២០០០ ចំពោះកូនត្រីមានទំហំពី ១-២ ស.ម
- កូនត្រីដែលដាក់បំប៉នត្រូវមានទំហំប៉ុនគ្នា បើមិនដូច្នេះទេកូនត្រីធំស៊ីកូនត្រីតូច និង កូនត្រីធំដណ្តើមចំណីកូនត្រីតូចស៊ី
- ចំពោះកូនត្រីទីឡាព្យ៉ា និង កូនត្រីឆ្ពិនអាចដាក់បំប៉នជាមួយគ្នាក៏បាន ដោយ ឡែកគ្នាក៏បាន
- តែចំពោះកូនត្រីកាបសាមញ្ញមិនត្រូវដាក់បំប៉នក្នុងហាប៉ាជាមួយកូនត្រីទីឡាព្យ៉ា និង កូនត្រីឆ្ពិនទេព្រោះធ្វើអោយកូនត្រីកាបសាមញ្ញលូតលាស់យឺតដោយ កូនត្រីទីឡាព្យ៉ា និង កូនត្រីឆ្ពិនដណ្តើមចំណីអស់ ។

☞ ដើម្បីងាយស្រួលក្នុងការរាប់លក់ និង កូនត្រីលូតលាស់ល្អ យើងគួរតែបំប៉នកូនត្រីដាច់ដោយឡែកៗពីគ្នាតាមប្រភេទនីមួយៗ ។



៤. ប្រភេទចំណីដែលត្រូវផ្តល់អោយកូនត្រី :

ដើម្បីអោយកូនត្រីឆាប់ធំធាត់យើងគួរយក :

- ត្រីចង្វា ឬកូនត្រីល្អិតៗយកមកហាលអោយស្ងួតហើយបុកអោយម៉ត់ លាយជាមួយកន្ទក់ម៉ត់
- ចំពោះម្សៅត្រី ២ខាំ អាចលាយជាមួយកន្ទក់ម៉ត់ ១គីឡូក្រាម
- ចំពោះវីតាមីន អា ដេ អឺ ១ខាំ អាចលាយជាមួយកន្ទក់ម៉ត់ ១ គីឡូក្រាម

រផ្តល់ចំណី :

ពីអោយកូនត្រី ២ ៣ ដងក្នុងមួយថ្ងៃ



៥. បរិមាណចំណី និង ការផ្តល់ចំណី :

- យើងគួរផ្តល់ចំណីអោយកូនត្រី ២-៣ ដងក្នុងមួយថ្ងៃ
- ការផ្តល់ចំណីគួរប្រព្រឹត្តទៅនៅពេលព្រឹក ថ្ងៃត្រង់ និង ល្ងាច
- បរិមាណចំណីយើងគួរពិនិត្យតាមការជាក់ស្តែង
- ជៀសវាងផ្តល់ចំណីតិចពេកនាំអោយកូនត្រីលូតលាស់យឺត

- ចំពោះកូនត្រី ២០០០ ក្បាលត្រូវផ្តល់ចំណីនៅសប្តាហ៍ទី១ ពីកន្លះខាំ ឬ កន្លះកំប៉ុងវាល់អង្ករក្នុងមួយថ្ងៃ ហើយនៅសប្តាហ៍ទី ២ត្រូវអោយពីកន្លះកំប៉ុង ទៅមួយកំប៉ុង
- ជៀសវាងផ្តល់ចំណីច្រើនពេកនាំអោយខាតបង់ និង ស្អុយទឹក



៦

៦. ចំណីធម្មជាតិ :

- ក្រៅពីចំណីបន្ថែម ចំណីធម្មជាតិ ( ប្លង់តុង ) មានសារៈសំខាន់ណាស់ចំពោះកូនត្រី
- យើងត្រូវតែប្រែទឹកក្នុងស្រះអោយមានពណ៌បៃតងជាចិន្នដោយប្រើជី អ៊ុយរ៉េលាយជាមួយ ដេ អា ប៉េ ជីលាមកសត្វ និង ជីធម្មជាតិនៅក្នុងស្រះ
- ជីអ៊ុយរ៉េ ៣ខាំ លាយជាមួយ ដេ អា ប៉េ ១ ខាំ ក្នុងផ្ទៃស្រះ ១០០ ម$^2$ ក្នុងមួយសប្តាហ៍ម្តងក្នុងករណីទឹកគ្មានពណ៌បៃតង·ចំពោះជីខាងលើនេះយើងត្រូវលាយជាមួយទឹកអោយរលាយទើបយកទៅបាចអោយសព្វលើផ្ទៃទឹកស្រះ
- ចំពោះជីលាមកសត្វ ត្រូវប្រើចំនួន ៥ គ.ក្រ ឬ ១ បង្គី ក្នុងមួយសប្តាហ៍
- ជីធម្មជាតិខែត្រ ២បាច់ដែលមានទំងន់ប្រហែល ១០ គីឡូក្រាមនៅតាម ជ្រុងស្រះ

- ជីលាមកសត្វត្រូវដាក់នៅកន្លែងទឹករាក់ហើយមានពន្លឺថ្ងៃគ្រប់គ្រាន់
- ករណីទឹកស្រះមានពណ៌បៃតងហើយ យើងត្រូវបញ្ឈប់ការប្រើប្រាស់ជី ហើយករណីទឹកលែងមានពណ៌បៃតងយើងត្រូវប្រើជីតាមបរិមាណខាងលើឡើងវិញ




៧. ការសំអាតហាប៉ា និង ថែទាំកូនត្រី :

- យើងត្រូវដុសសំអាតហាប៉ា ២ ដងក្នុងមួយអាទិត្យ ដោយប្រើដៃដុសថ្នមៗ
- មិនត្រូវប្រើ ច្រាសរឹងដុសហាប៉ាឡើយនាំអោយរហែកហាប៉ា
- ការសំអាតនេះគឺធ្វើអោយប្លង់តុងអាចចូលទៅក្នុងហាប៉ាបានច្រើន និង ធើអោយទឹកផ្លាស់ប្តូរនៅក្នុងហាប៉ា
- យើងគួរឧស្សាហ៍ត្រួតពិនិត្យហាប៉ាក្រែងមានកន្លែងរហែកធ្លុះធ្លាយ
- ត្រូវការពារកុំអោយមានត្រីកាច ពស់ កង្កែប ចាប ឬ កណ្តុរ ចូលក្នុងហាប៉ាស៊ីកូនត្រី
- ត្រូវប្តូរទីតាំងហាប៉ា ទៅរកកន្លែងថ្មីសមស្រប ករណីកន្លែងចាស់រាក់ពេក

- ករណីមានភ្លៀងយើងត្រូវប្រុងប្រយ័ត្នក្រែងទឹកលិចហាប៉ានាំអោយកូនត្រីចេញ
- ក្នុងករណីទឹកស្រះមានស្លែអណ្តែតគ្រាក្នុងហាប៉ាយើងត្រូវកៀរចេញ
- ដើម្បីផលិតកូនត្រីអោយបានច្រើន និង ឆាប់ធំធាត់កសិករត្រូវបំប៉នកូនត្រី





១



## II. ការចិញ្ចឹមកូនត្រីនៅក្នុងស្រះ

### ១. ស្រះសមស្របសំរាប់បំប៉នកូនត្រី :

- ជាកន្លែងស្រឡះល្អពុំមានដើមឈើដុះស៊ុបទ្រុប
- មានទីតាំងនៅជិតផ្ទះងាយស្រួលក្នុងការគ្រប់គ្រង
- ស្រះបំប៉នកូនត្រីគួរមានទំហំពី ៥០ ទៅ ២០០ ម$^{២}$ និង មានជំរៅ កន្លះម៉ែត្រ ទៅ១ ម ។
- ស្រះអាចស្តុកទឹកបានយូ និង មានគុណភាពល្អ
- មិនលិចទឹកនៅរដូវវស្សា

### ២. ការរៀបចំស្រះបំប៉ន :

- បូមទឹក និង ចាប់ត្រីស្រែចេញ
- ស្តារភក់បាតស្រះ
- សំអាតរុក្ខជាតិដែលដុះជុំវិញស្រះ
- បន្ទាប់ពីមានទឹកនៅក្នុងស្រះហើយ កសិករត្រូវប្រើ កំបោរសពី ៩-១២ គ.ក្រ ក្នុង ១០០ ម$^{២}$ ចំពោះស្រះចាស់ និង ពី ៦-៩ គ.ក្រ ក្នុង ១០០ម$^{២}$ ចំពោះស្រះថ្មី
- ក្រោយពីបាចកំបោរសបានពី ៤-៧ ថ្ងៃយើងត្រូវដាក់ជីកែប្រែគុណភាពទឹក ដើម្បីបង្កើនចំណីធម្មជាតិក្នុងបរិមាណ :
  - ជីលាមកសត្វ ២-៣ បង្គី
  - រុក្ខជាតិបៃតង ( ទន្រ្ទានខែត្រ សណ្តែកអង្រៃ ) ២-៣ បាច់
  - ជី អ៊ុយរ៉េ ៣ ខាំ
  - ជី ដេ អា ប៉េ ១ ខាំ



១០

៣. ការលែងកូនត្រី និង ការផ្តល់ចំណី :

- បន្ទាប់ពីទឹកស្រះមានពណ៌បៃតងហើយ យើងអាចលែងកូនត្រីបាន
- កូនត្រីដែលត្រូវយកមកលែងក្នុងស្រះត្រូវមានទំហំ ពី ១- ២ ស.ម ឬ មាន អាយុពី ១០-១៥ ថ្ងៃ
- ចំនួនកូនត្រីត្រូវលែងពី ៦០-៧០ក្បាល ក្នុង១ ម$^{២}$
- ត្រូវផ្តល់ចំណីអោយកូនត្រីពី ២-៣ ដងក្នុង១ថ្ងៃ
- ការផ្តល់ចំណីគួរប្រព្រឹត្តទៅនៅពេលព្រឹក ថ្ងៃត្រង់ និង ល្ងាច ពេលមេឃស្រលះ និង គ្មានភ្លៀង
- បរិមាណចំណីកសិករគួរពិនិត្យតាមការជាក់ស្តែង
- ជៀសវាងផ្តល់ចំណីច្រើនពេកនាំអោយខាតបង់ និង ស្អុយទឹក
- ជៀសវាងផ្តល់ចំណីតិចពេកនាំអោយកូនត្រីមានការលូតលាស់យឺត

- ត្រូវលែងកូនត្រីដែលមានទំហំប៉ុនគ្នាបើពុំនោះទេ កូនត្រីធំស៊ីកូនត្រីតូច និង ដណ្តើមចំណីពីកូនត្រីតូច

☞ វិធីសាស្ត្រលែងកូនត្រី :

ការលែងកូនត្រីមាន ៣ដំណាក់កាល :

១. ត្រាំថង់កូនត្រីក្នុងទឹកស្រះអោយបានពី ១០-១៥ នាទី

២. ស្រាយមាត់ថង់រួចបាចទឹកបញ្ចូលក្នុងថង់កូនត្រីថ្នមៗ

៣. ផ្ទៀងមាត់ថង់ដើម្បី អោយកូនត្រីហែលចេញតាមសំរួល



៤. ការថែទាំ :

- ត្រូវការពារកុំអោយមានត្រីកាច ពស់ កណ្តុរ កង្កែប និង សត្វផ្សេងទៀតដែលស៊ី នងិ បំផ្លាញត្រី
- ត្រូវលើកទំនប់ស្រះអោយបានខ្ពស់កុំអោយលិចទឹក
- ត្រូវផ្តល់ចំណីអោយបានទៀងទាត់ និង ត្រូវដាក់ជីបន្ថែមក្នុងករណីទឹកមិនមាន

ពណ៌បៃតង

- ករណីក្នុងស្រះមានកូនសត្វល្អិតច្រើន យើងត្រូវបាចប្រេងកាត ពី ៣-៤ ស្លាបព្រា លើផ្ទៃទឹកស្រះ ១០០ ម^២ (ត្រូវបាចពីលើខ្យល់)

៥. ការប្រមូលផល និង ការលក់កូនត្រី :

- ពេលកូនត្រីមានទំហំពី ៣-៤ ស.ម ឬ ពី២-៣ ថ្នាំងដៃ យើងអាចចាប់លក់ និងយកទៅចិញ្ចឹមបាន
- យើងត្រូវអូស ឬ កៀរកូនត្រីដាក់ក្នុងហាប៉ា
- មិនត្រូវផ្តល់ចំណីអោយកូនត្រីនៅថ្ងៃចាប់វាលក់ ឬ ដឹកជញ្ជូនទេ
- មិនត្រូលក់កូនត្រីទៅអោយកសិករណាដែលស្រះរបស់គាត់មានត្រីស្រែ
- ដើម្បីយកកូនត្រីធំលក់ យើងត្រូវប្រើកញ្រ្ចែង ឬ ការូសំរាប់ច្រោះវា






## III. ការដឹកជញ្ជូនកូនត្រី :

### ១. ការដឹកជញ្ជូនដោយប្រើថង់ផ្លាស្ទិច :

- ការដឹកជញ្ជូននេះអាចប្រើសំរាប់ផ្លូវឆ្ងាយដោយប្រើខ្យល់ធម្មជាតិ
- ថង់ផ្លាស្ទិចដែលកសិករនិយមប្រើមានទំហំ ៦០ ស.ម x ៨០ ស.ម
- យើងគួរប្រើថង់ផ្លាស្ទិច ២ជាន់ទើបប្រសើរ
- ត្រូវដាក់ទឹកស្រះ ១ភាគ៣ នៃថង់រួចដាក់កូនត្រីពី ២០០-៣០០ ក្បាល ក្នុងមួយថង់
- បន្ទាប់ពីដាក់កូនត្រីរួចហើយត្រូវទាញមាត់ថង់ចំហអោយខ្យល់ចូល រួចក្រួបមាត់ថង់ហើយយកកៅស៊ូកងចងមាត់ថង់អោយជាប់
- មិនត្រូវផ្តល់ចំណីអោយកូនត្រីនៅថ្ងៃចាប់វាលក់ ឬ ដឹកជញ្ជូន ព្រោះបើកូនត្រីស៊ីចំណីឆ្អែត វានឹងបញ្ចេញលាមកនៅក្នុងថង់ដែលបណ្តាល អោយកូនត្រីពុល នឹងងាប់បាន
- ត្រូវត្រៀមកញ្ជេ ឬ ជាលហើយទ្រាប់សំបកបារ៉ូរួចដាក់ថង់កូនត្រីទៅក្នុងជាល ឬ កញ្ជេនោះដើម្បីការពារកុំអោយថង់ធ្លាយ


ដាក់ទឹកមួយភាគបួន


របៀបបញ្ចូលខ្យល់


របៀបចាប់ក្រួច


របៀបចងមាត់ថង់


ថង់កូនត្រីចងរួច

២. ការដឹកជញ្ជូនដោយធុង ឬ ឆ្នាំង :

- ការដឹកជញ្ជូនរបៀបនេះសំរាប់ដឹកជញ្ជូនផ្លូវជិត ឬ ពីភូមិមួយទៅភូមិមួយ
- មុនដំបូងត្រូវដាក់ទឹកស្រះចំនួ ១ភាគ៣ ទៅក្នុងឆ្នាំង ឬ ធុងនោះ
- ហើយកសិករអាចរែក ឬ កល្បេត ទុល កូនត្រីនោះបាន
- ដើម្បីកំអោយកូនត្រីលោតចេញពីក្នុង ធុង ត្រូវប្រើស្បៃ ឬ ក្រមាគ្រប់ពីលើ ។







## សន្និដ្ឋាន

វគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសបំប៉នកូនត្រី ក្នុងហាប៉ា និង ក្នុងស្រះបានប្រព្រឹត្តទៅរយះពេល២ ថ្ងៃប្រកបដោយជោគជ័យ និង ទទួលបានលទ្ធផលល្អប្រសើរ ។ ដោយផ្អែកទៅលើការបណ្តុះបណ្តាល និង ផ្តល់បទពិសោធន៍របស់គ្រូកសិករ និង បុគ្គលិករបស់អង្គការ ស៊ី អារ អែស យើងសង្កេតឃើញ សិក្ខាកាមមានការចាប់អារម្មណ៍ខ្លាំងទៅលើប្រធានបទ និង បានផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ។ ម្យ៉ាងទៀតសិក្ខាកាមបានបង្កើនចំណេះដឹងបន្ថែមតាមរយះការអនុវត្តជាក់ស្តែងទៅលើសកម្មភាពបំប៉នកូនត្រី ហើយនឹងអាចយកចំណេះដឹងទាំងនេះទៅអនុវត្តនៅតាមភូមិដោយខ្លួនឯងបាន ។

# កម្មវិធីបណ្តុះបណ្តាល

| ពេលវេលា | ប្រធានបទ | អ្នកចូលរួម |
|---|---|---|
| **ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០២ ការបំប៉នកូនត្រីក្នុងហាប៉ា** | | |
| ៨:០០-៩:០០ | - ការណែនាំអោយស្គាល់គ្នា<br>- បង្កើតគោលបំណង<br>- បង្កើតសេចក្តីរំពឹងទុក<br>- សំនួរសាកល្បង | - យឹម ឡុងឌី |
| ៩:០០-៩:១៥ | - សំរាក | |
| ៩:១៥-៩:២៥ | - ល្បែងថាមពល | |
| ៩:២៥-១២:០០ | - ការដេរហាប៉ា<br>- ការតំឡើងហាប៉ាក្នុងស្រះ<br>- ដង់ស៊ីតេកូនត្រីដែលត្រូវដាក់បំប៉នក្នុងហាប៉ា | - ភោគ សុខ |
| ១២:០០-១:៣០ | - អាហារថ្ងៃត្រង់ | |
| ១:៣០-២:០០ | - រំលឹកមេរៀន | - ភោគ សុខ |
| ២:០០-៥:០០ | - ប្រភេទចំណីដែលត្រូវផ្តល់អោយកូនត្រី<br>- ចំនួនកូនត្រី និង ការអោយចំណី<br>- ចំណីធម្មជាតិ<br>- ការសំអាតហាប៉ា និង ត្រួតពិនិត្យកូនត្រី | - ភោគ សុខ |
| **ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២ ការបំប៉នកូនត្រីក្នុងស្រះ** | | |
| ៨:០០-៩:០០ | - រំលឹកមេរៀន | - យឹម ឡុងឌី |
| ៩:០០-១២:០០ | - ស្រះសមស្របក្នុងការបំប៉នកូនត្រី<br>- ការរៀបចំស្រះ<br>- ការលែងកូនត្រី<br>- ការត្រួតពិនិត្យស្រះ និង កូនត្រី<br>**ការដឹកជញ្ជូនកូនត្រី**<br>- ការដឹកជញ្ជូនដោយប្រើថង់ផ្លាស្ទិច<br>- ការដឹកជញ្ជូនដោយប្រើធុង ឬ ឆ្នាំង | - យឹម ឡុងឌី<br>- ញ៉ាញ់ សំអឿន |

| | | |
|---|---|---|
| ១២:០០-១:៣០ | - អាហារថ្ងៃត្រង់ | |
| ១:៣០-២:០០ | - ល្បែងថាមពល<br>- រំលឹកមេរៀន | - ញ៉ាញ់ សំអឿន |
| ២:០០-៥:០០ | - ការអនុវត្តជាក់ស្តែង<br>- សំនួរសាកល្បង | - ឡុងឌី សំអឿន<br>- ភោគ សុខ |

## បញ្ជីឈ្មោះអ្នកចូលរួម

| ល.រ | ឈ្មោះកសិករ | ភេទ | ភូមិ | ផ្សេងៗ |
|---|---|---|---|---|
| ១ | ងួន ធឿន | ប | កំពោតប្រស់ | ធ្លាប់បានបំប៉ន |
| ២ | ទេព រ៉ាដូ | ប | សាលាទាន | ធ្លាប់បានបំប៉ន |
| ៣ | រត្ន័ ប៊ុនធឿន | ប | ពោធិ៍ថ្មី | ធ្លាប់បានបំប៉ន |
| ៤ | នង ហ៊ុន | ស | - | កសិករស្ត្រី |
| ៥ | ស សុផាត | ស | ថ្នល់ទទឹង | កសិករស្ត្រី |
| ៦ | ប៊ុង ជិត | ប | - | ធ្លាប់បានបំប៉ន |
| ៧ | ឥណ ឡេង | ប | ទាហ៊ានក្រោម | ធ្លាប់បានបំប៉ន |

## តារាងពិន្ទុសំនួរសាកល្បង

| ល.រ | ឈ្មោះ | ពិន្ទុមុនពេលរៀន | ពិន្ទុក្រោយពេលរៀន | ពិន្ទុកើនឡើង |
|---|---|---|---|---|
| ១ | រត្ន័ ប៊ុនធឿន | ៩០ | ១០០ | ១០ |
| ២ | ប៊ុង ជិត | ៩០ | ៩០ | ០ |
| ៣ | ឥណ ឡេង | ៨០ | ១០០ | ២០ |
| ៤ | ទេព រ៉ាដូ | ៧៥ | ១០០ | ២៥ |
| ៥ | ងួន ធឿន | ៤៥ | ៩០ | ៤៥ |
| ៦ | នង ហ៊ុន | ៤០ | ១០០ | ៦០ |
| ៧ | ស សុផាត | ៣០ | ៨០ | ៥០ |



ការបណ្តុះបណ្តាលរបស់កសិករផលិត



ការបង្ហាញផ្ទាំងរូបភាព



ការដេរហាប៉ា



ការតំឡើងហាប៉ាក្នុងស្រះ



ការផ្សំចំណីកូនត្រី